របាយការណ៍ប្រចាំឆ្នាំ

២០២៥

រចនាសម្ព័ន្ធ
ប្រចាំឆ្នាំ
២០២៥

មាតិកា

១	សាររបស់ឆាយិការប្រតិបត្តិ	៤
២	ខ្លឹៗ អំពីអង្គការកុមារ	៥
៣	គម្រោងសាងសង់បន្ទប់ទឹកស្អាត	៦
៤	គម្រោងធិវាការស្តាប់ព្រួកម្ពុជា	១០
៥	គម្រោងពិនិត្យ និងព្យាបាល ត្រចៀក ច្រមុះ បំពង់ក ដោយឥតគិតថ្លៃ	១២
៦	គម្រោងថែទាំ សុខភាព និងសុខុមាលភាពកុមារ	១៣
៧	គម្រោងប្រតិបត្តិការព្យាបាលអ្នកជំងឺផ្លូវចិត្តដែលចងបង្ខាំងទុក	១៤
៨	គម្រោងគាំទ្រផ្លូវចិត្តដល់ស្ត្រី និងកុមារដែលរងផលប៉ះពាល់ដោយសារជម្លោះព្រំដែនកម្ពុជា-ថៃ	១៦
៩	គម្រោងជួសជុលមណ្ឌលគាំពារកុមារ អង្គការគ្រួសារថ្មី តាខ្មៅ	១៨
១០	គម្រោងសាងសង់អគារសិក្សា	១៩
១១	កម្មវិធីអំណោយសប្បុរសធម៌	២០
១២	កម្មវិធីជំនួយឧបត្ថម្ភផ្សេងៗ	២៥

១. សាររបស់នាយិការប្រតិបត្តិ



យើងខិតខំប្រឹងប្រែង ទាំងគំនិត ប្រាជ្ញា និងពេលវេលា ដើម្បីគ្រប់គ្រង ចាត់ចែង ធនធានខាងក្នុង ជំនួយពីដៃគូរសហការ ព្រមទាំងកិច្ចសម្របសម្រួលដល់ការបរិច្ចាគពីក្រៅប្រទេស ដើម្បីសកម្មភាពលើកកម្ពស់សុខភាព សុខុមាលភាព និងផលប្រយោជន៍របស់ស្ត្រី និងកុមារកម្ពុជាដែលខ្វះខាត។ យើងឃើញពីតម្រូវការសម្រាប់កិច្ចការសប្បុរសធម៌ ដែលត្រូវផ្តោតការយកចិត្តទុកដាក់ ខណៈដែលពិភពលោកកំពុងពោរពេញទៅដោយបញ្ហាចាក់ស្រេះរាប់មិនអស់។ រាល់ការខិតខំប្រឹងប្រែងដែលមិនផ្តោតទៅលើយុទ្ធសាស្ត្រត្រឹមត្រូវ នឹងមិនទទួលបានលទ្ធផលល្អឡើយ។ យើងបានផ្តោតការយកចិត្តទុកដាក់ទៅលើតម្រូវការទាំងឡាយណា ដែលមិនទាន់បានផ្តល់ ឬបានដោះស្រាយដោយភាគីពាក់ព័ន្ធសំខាន់ៗផ្សេងទៀត។

ការផ្តោតការយកចិត្តទុកដាក់ទៅលើតម្រូវការរបស់ស្ត្រី យុវជន និងកុមារ នឹងនាំមកនូវការផ្លាស់ប្តូរយ៉ាងធំសម្រាប់សង្គមជាតិទាំងមូល។ តាមរយៈការជួយដល់ស្ត្រី និងអ្នកជំនាន់ក្រោយ នឹងជួយជំរុញអនាគត និងសហគមន៍ដែលពួកគេរស់នៅឲ្យមានភាពកាន់តែប្រសើរឡើង។ ហើយទស្សនៈនេះបានបង្កើតនូវចក្ខុវិស័យដ៏ច្បាស់លាស់មួយគឺ “ការផ្តល់សិទ្ធិអំណាចដល់កុមារកម្ពុជាដែលខ្វះខាត ឲ្យមានឱកាសដូចមនុស្សគ្រប់រូបដោយធ្វើឲ្យមានភាពកាន់តែប្រសើរឡើង ដើម្បីអនាគត និងសហគមន៍របស់ពួកគេ” ហើយកិច្ចការនេះបានចូលរួមបណ្តុះស្មារតីសប្បុរសធម៌ដល់មនុស្សជំនាន់ក្រោយ។

យើងសូមកោតសរសើរដល់បណ្តាដៃគូរសហការ ដែលបានទាំមកជាមួយនូវចំណេះ ជំនាញ បច្ចេកទេសដើម្បីជំរុញដល់កិច្ចសហប្រតិបត្តិការ ប្រកបដោយប្រសិទ្ធភាព និរន្តរភាព និងនាំមកនូវអត្ថប្រយោជន៍ដ៏ធំធេងដល់ស្ត្រី និងកុមារដែលខ្វះខាត។ អង្គការរក្សាកុមារ បានបង្កើតឡើងដើម្បីឆ្លើយតបទៅនឹងតម្រូវការទាំងនេះ ហើយបានក្លាយជាយាន្តចម្ងង ដែលអាចផ្តល់ជាមូលនិធិ និងធ្វើជាដៃគូរសហការជាមួយបណ្តាគម្រោង ឬអង្គការដែលបានចែករំលែកចក្ខុវិស័យ និងបេសកកម្មរបស់ខ្លួន។



យើងបានរួមបញ្ចូលគ្នានូវភាពជាដៃគូរ ក្នុងវិស័យអប់រំ និងវិស័យសុខាភិបាលដោយបាន អនុវត្តយ៉ាងខ្ជាប់ខ្ជួនលើការគ្រប់គ្រងគម្រោង របាយការណ៍ វាយតម្លៃ និងគោលការណ៍ណែនាំសម្រាប់គណនេយ្យភាពហិរញ្ញវត្ថុ អនុលោមភាព ដើម្បីភាពជោគជ័យនៃគម្រោងនីមួយៗ។ យើងសូមថ្លែងអំណរគុណដល់បណ្តាដៃគូរម្ចាស់ជំនួយ សម្រាប់ឱកាសនៃភាពជាដៃគូរសហការ ក្នុងវិស័យអប់រំ វិស័យសុខាភិបាល និងវិស័យដ៏ទៃទៀត ហើយតាមរយៈបទពិសោធន៍ទាំងនេះបានជម្រុញឲ្យទស្សនៈនៃការចែករំលែករបស់យើងវិវត្តទៅរកភាពទុកចិត្ត និងជឿជាក់យ៉ាងជ្រាលជ្រៅ ដែលបានចូលរួមចំណែក មិនត្រឹមតែជាជំនួយសប្បុរសធម៌ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងស្មារតីនៃមនុស្សធម៌ផងដែរ ដែលផុសចេញពីចិត្ត និងបេះដូង។ យើងសង្ឃឹម និងជឿជាក់ទៅលើកការចូលរួម ការចែករំលែកនូវអំណោយទានដ៏មានសារៈសំខាន់នេះ ហើយការរួមសហការគ្នាជាដៃគូរនឹងជួយជម្រុញការអភិវឌ្ឍឲ្យកាន់តែមានភាពប្រសើរឡើង។

ដោយក្តីគោរពស្រលាញ់ និងរាប់អានយ៉ាងជ្រាលជ្រៅ។

សុខ ឥណ្ណសិកា
នាយិការប្រតិបត្តិ

២. ខ្លីៗ អំពីអង្គការអក្សាកុមារ

អំពីអង្គការអក្សាកុមារ

អង្គការអក្សាកុមារ (“អ.ស.ក”) គឺជាអង្គការដែលបានចុះបញ្ជីស្របច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានបេសកកម្មផ្សព្វផ្សាយសកម្មភាពមនុស្សធម៌ និងសប្បុរសធម៌ ចូលរួមផ្តល់សិទ្ធិអំណាចដល់កុមារកម្ពុជាដែលខ្វះខាត ឱ្យមានឱកាសដូចមនុស្សគ្រប់រូប ដោយធ្វើឱ្យមានភាពកាន់តែប្រសើរឡើង ដើម្បីអនាគត និងសហគមន៍របស់ពួកគេ។

ចក្ខុវិស័យ

ផ្តល់សិទ្ធិអំណាចដល់កុមារកម្ពុជាដែលខ្វះខាត ឱ្យមានឱកាសដូចមនុស្សគ្រប់រូប ដោយធ្វើឱ្យមានភាពកាន់តែប្រសើរឡើង ដើម្បីអនាគត និងសហគមន៍របស់ពួកគេ។

បេសកកម្ម

លើកកម្ពស់សុខភាព សុខុមាលភាព និងផលប្រយោជន៍ របស់កុមារកម្ពុជាពីគ្រប់មជ្ឈដ្ឋាន។

សកម្មភាពរបស់ (“អ.ស.ក”) គឺការធ្វើការរួមគ្នា តាមរយៈកិច្ចសហប្រតិបត្តិការ ជាមួយអង្គការក្នុងស្រុក និងអង្គការអន្តរជាតិ ដែលបានចែករំលែកទស្សនៈវិស័យ និងបេសកកម្មជាមួយនឹងអង្គការ។

ម្ចាស់ជំនួយ – ២០២៥

ដៃគូរសហការ – ២០២៥

៣. គម្រោងសាងសង់បន្ទប់ទឹកស្អាត

- **សាលាបឋមសិក្សា ស្នោ-ឃ្លូ**

នាខែមករា ឆ្នាំ២០២៥ អង្គការរក្សាកុមារ បានបញ្ចប់ការសាងសង់គម្រោងបន្ទប់ទឹកស្អាតជាលើកដំបូងបំផុតរបស់ខ្លួន នៅក្នុងសាលាបឋមសិក្សាស្នោ—ឃ្លូ ស្ថិតនៅក្នុងស្រុកសន្ទុក ខេត្តកំពង់ធំ ដែលមានបង្គន់ថ្មីចំនួន ១០ រួមទាំងបង្គន់សម្រាប់ជនមានពិការភាពចំនួន ១ ផងដែរ។ គម្រោងសាងសង់បន្ទប់ទឹកស្អាតនេះទទួលបានការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុ ពីធនាគារ ស៊ុនហាន (ខេមបូឌា) ម.ក និងក្រុមហ៊ុន Autobahn VAG Co., Ltd











▪ វិទ្យាល័យតាំងក្រសាំង

នាដើមខែតុលា ឆ្នាំ២០២៥ អង្គការរក្សាកុមារ បានបញ្ចប់គម្រោងសាងសង់បន្ទប់ទឹកស្អាតមួយទៀតនៅក្នុង វិទ្យាល័យតាំងក្រសាំង ស្ថិតនៅក្នុងស្រុកសន្ទុក ខេត្តកំពង់ធំ ដែលមានបង្គន់ថ្មីចំនួន ៦ រួមទាំងបង្គន់សម្រាប់ជនមានពិការភាពចំនួន ១។ គម្រោងសាងសង់នេះ ឧបត្ថម្ភថវិកាដោយក្រុមហ៊ុន Autobahn VAG Co., Ltd សហការជាមួយនិងក្រុមហ៊ុន Tri Dung Co., Ltd







- **សាលាបឋមសិក្សាតាំងក្រសាំង**

នាចុងខែតុលា ឆ្នាំ២០២៥ អង្គការរក្សាកុមារ បានបញ្ចប់ការសាងសង់បន្ទប់ទឹកស្អាតចំនួនមួយខ្នងទៀត នៅក្នុងសាលាបឋមសិក្សាតាំងក្រសាំង ស្ថិតនៅក្នុងស្រុកសន្ទុក ខេត្តកំពង់ធំ ដែលមានបង្គន់ថ្មីចំនួន៨ រួមទាំងបង្គន់សម្រាប់ជនមានពិការភាព ក្រោមមូលនិធិសាងសង់របស់ធនាគារ ស៊ុនហាន (ខេមបូឌា) ម.ក។







ស្ថាបត្យកម្មសម្រាប់បង្គន់អនាម័យត្រូវបានរចនាតាមបែបបុរាណ ប៉ុន្តែប្រកបដោយភាពច្នៃប្រឌិត ដែលមានទ្វារបន្ទប់បង្គន់ឯកជន កន្លែងលាងដៃរួមគ្នា ហើយផ្នែកដ៏ល្អបំផុតអំពីបន្ទប់ទឹកស្អាតគឺ ទីធ្លាធំទូលាយ មានពន្លឺគ្រប់គ្រាន់ មានបន្ទប់ទឹកដាច់ដោយឡែកសម្រាប់សិស្សប្រុស សិស្សស្រី និងសម្រាប់ជនមានពិការភាព។ សួនផ្កាតូចមួយ ប្រកបដោយភាពទាក់ទាញ ត្រូវបានបង្កើតឡើង ដែលបានបន្ថែមភាពស្រស់ស្អាតមួយកម្រិតទៀតសម្រាប់សំណង់អគារនេះផងដែរ។ សំណង់អគារបន្ទប់ទឹកស្អាតក៏ត្រូវបានរចនាឡើង ដោយផ្តោតទៅលើសុវត្ថិភាព និងសុខភាព ដែលរួមមានទីតាំង (រវាងចន្លោះអគារ) សុវត្ថិភាព និងអនាម័យ ភាពធន់ និងសោភ័ណភាព ដែលអាចផ្តល់នូវ បរិយាកាសស្អាប់ស្ងាត់ អនាម័យ និងផាសុខភាព។

សំណង់អគារបន្ទប់ទឹកស្អាតនេះ បានបំបែកកំណត់ត្រារបស់សាលារៀន ដែលបង្ហាញថាការអវត្តមានរបស់សិស្សានុសិស្សបានធ្លាក់ចុះ ជាពិសេសក្នុងចំណោមក្មេងស្រីជំទង់ដែលរងផលប៉ះពាល់ខ្លាំងបំផុត ដោយការមិនមានបន្ទប់ទឹកស្អាតប្រើប្រាស់។ សិស្សានុសិស្សកាន់តែច្រើន បានស្នើសុំផ្ទេរចូលរៀនក្នុងសាលា ដើម្បីបានប្រើប្រាស់បន្ទប់ទឹកស្អាត។ អ្វីដែលកាន់តែប្រសើរនោះគឺ សិស្សានុសិស្សមានសុខភាពល្អ មិនឈឺញឹកញាប់ មានការយកចិត្តទុកដាក់ក្នុងថ្នាក់រៀន មានមោទនភាព ហើយសប្បាយរីករាយក្នុងការមកកាន់ថ្នាក់រៀន។









៤. គម្រោងទិវាការស្តាប់ឮកម្ពុជា



អង្គការរក្សាកុមារបានប្រារព្ធទិវាស្តាប់ឮកម្ពុជា នៅខែមីនា ឆ្នាំ២០២៥ ក្រោមប្រធានបទ៖ "បង្កើនអានុភាពសម្រាប់តម្លៃទាំត្រចៀក និងការស្តាប់ឮ"។ ទិវានេះបានប្រារព្ធធ្វើឡើង នៅវិទ្យាល័យអប់រំពិសេសភ្នំពេញថ្មី ដោយមានសកម្មភាពមួយចំនួនដូចជា៖ ការចែកអាវយឺតដល់អ្នកចូលរួម ការផ្តល់ការពិនិត្យ និងព្យាបាល ត្រចៀក និងផ្តល់ឧបករណ៍ជំនួយការស្តាប់ សម្រាប់អ្នកមានបញ្ហាការស្តាប់ឮដោយឥតគិតថ្លៃ ការបរិច្ចាគសៀវភៅដល់បណ្ណាល័យព្រមទាំងឈុតតុ និងកៅអីដល់ថ្នាក់ មត្តេយ្យសិក្សាសម្រាប់សិស្សមានពិការភាពគថ្លង់ ការធ្វើបទបង្ហាញស្តីពីការបណ្តុះបណ្តាល តំរង់ទិសការងារ និងបទបង្ហាញស្តីពី ការយល់ដឹងអំពីការថែទាំត្រចៀកដល់សិស្សមានពិការភាពគថ្លង់។ ទិវានេះមានអ្នកចូលរួមសរុបចំនួន ៥០០ រូប។ គណៈអធិបតីនិងភ្ញៀវកិត្តិយសអញ្ជើញចូលរួមក្នុងទិវារួមមាន៖ មន្ត្រីជាន់ខ្ពស់រាជរដ្ឋាភិបាល តំណាងមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ តំណាងការិយាល័យអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រៅប្រព័ន្ធ តំណាងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងឃុំរនីតិសម្បទារាជធានីភ្នំពេញ តំណាងក្រុមប្រឹក្សាសកម្មភាពជនពិការ តំណាងធនាគារជាតិនៃកម្ពុជា មជ្ឈមណ្ឌលកុមារកំព្រា តំណាងអង្គការដៃគូ កុមារ និងមនុស្សពេញវ័យដែលបាត់បង់ការស្តាប់ឮ លោកគ្រូ អ្នកគ្រូ អាណាព្យាបាលសិស្សដែលបាត់បង់ការស្តាប់ឮ ព្រមទាំងអ្នកសារពត៌មានជាតិ ដើម្បីផ្តិតយកព្រឹត្តិការណ៍ នៃទិវាស្តាប់ឮកម្ពុជា។






CELEBRATING CAMBODIA
HEARING DAY 2023
Changing mindsets:
Empower yourself to make ear and hearing
care a reality for all!











៥. គម្រោងពិនិត្យ និងព្យាបាល ត្រចៀក ច្រមុះ បំពង់ក ដោយឥតគិតថ្លៃ



អង្គការរក្សាកុមារ បានផ្តល់មូលនិធិដល់អង្គការផ្តល់នូវក្តីសង្ឃឹមកម្ពុជា សម្រាប់គម្រោងពិនិត្យ និងព្យាបាល ត្រចៀក ច្រមុះ បំពង់ក និងផ្តល់ឧបករណ៍ជំនួយការស្តាប់សម្រាប់អ្នកមានបញ្ហាការស្តាប់ឮ ដោយឥតគិតថ្លៃ។

គោលបំណងនៃគម្រោងនេះគឺដើម្បីបង្កើនការយល់ដឹងអំពីការថែទាំត្រចៀក និងការស្តាប់ឮ ការពិនិត្យ និងព្យាបាល ត្រចៀក ច្រមុះ បំពង់ក ការបំពាក់ឧបករណ៍ជំនួយការស្តាប់ដែលសមស្រប សម្រាប់អ្នកដែលមានការបាត់បង់ការស្តាប់ឮ ដោយរួមបញ្ចូលទាំងសេវាថែទាំបន្ទាប់ពីការពិនិត្យ និងព្យាបាលរួច។










៦. គម្រោងថែទាំ សុខភាព និងសុខុមាលភាពកុមារ



អង្គការរក្សាកុមារ បានផ្តល់ជំនួយហិរញ្ញវត្ថុដល់អង្គការគ្រួសារថ្មី សម្រាប់គម្រោងសុខភាព និងអនាម័យ ជាពិសេសលើការចំណាយទាក់ទងនឹងគ្រួសារ និងអ្នកមើលថែទាំកុមារអំឡុងពេលសម្រាកព្យាបាលនៅមន្ទីរពេទ្យ។

គម្រោងនេះបានផ្តល់អត្ថប្រយោជន៍ដល់កុមារ និងគ្រួសាររបស់ពួកគេ នៅមណ្ឌលទាំងប្រាំមួយរបស់អង្គការគ្រួសារថ្មី ដែលមានទីតាំងស្ថិតនៅ ភ្នំពេញ តាខ្មៅ សៀមរាប និងប៉ោយប៉ែត។ ការគាំទ្រនេះនឹងចូលរួមចំណែកក្នុងការអភិវឌ្ឍនៃការទទួលបានសេវាសុខភាពប្រកបដោយគុណភាព និងបរិយាបន្នសង្គម ដែលជួយលើកកំពស់ជីវភាពរបស់កុមារកម្ពុជា ព្រមទាំងផ្តល់អនាគតមួយប្រកបដោយក្តីសង្ឃឹមសម្រាប់ពួកគេ។







៧. គម្រោងប្រតិបត្តិការព្យាបាលអ្នកជំងឺផ្លូវចិត្តដែលចងបង្ខាំងទុក



អង្គការរក្សាកុមារបានផ្តល់ជំនួយហិរញ្ញវត្ថុដល់អង្គការចិត្តសង្គមអន្តរវប្បធម៌ កម្ពុជាសម្រាប់គម្រោងប្រតិបត្តិការព្យាបាលអ្នកជំងឺផ្លូវចិត្តដែលចងបង្ខាំងទុក។ គោលបំណងនៃគម្រោងគឺ៖ (១) ដើម្បីលើកកំពស់សុខភាពផ្លូវចិត្ត និងជួយអ្នកជំងឺផ្លូវចិត្តដែលត្រូវគេចងបង្ខាំងទុកជាយថាហេតុ ព្រោះតែជំងឺផ្លូវចិត្តរបស់ពួកគេ ឬព្រោះតែកង្វះខាតលទ្ធភាពទទួលបាននូវសេវាព្យាបាលផ្លូវចិត្តដែលសមស្រប។ (២) លើកកំពស់ការយល់ដឹងអំពីបញ្ហាសុខភាពផ្លូវចិត្ត នៅតាមតំបន់ជនបទនៅកម្ពុជា ហើយបង្ហាញឲ្យដឹងថាអាចមានវិធីផ្សេងជំនួសឲ្យការចងបង្ខាំងទុកបុគ្គល មានជំងឺផ្លូវចិត្តធ្ងន់ធ្ងរ និងរ៉ាំរ៉ៃ។














11
He was locked up in thisroom

The family attened traditional ceremony after he
is unchained and integrated into family



៨. គម្រោងគាំទ្រផ្លូវចិត្តដល់ស្ត្រី និងកុមារដែលរងផលប៉ះពាល់ដោយសារជម្លោះព្រំដែនកម្ពុជា-ថៃ



អង្គការរក្សាកុមារ បានផ្តល់ជំនួយហិរញ្ញវត្ថុ ដែលបានឧបត្ថម្ភដោយ ធនាគារស៊ិនហាន (ខេមបូឌា) ម.ក ដល់អង្គការចិត្តសង្គមអន្តរវប្បធម៌ កម្ពុជា សម្រាប់ "គម្រោងគាំទ្រផ្លូវចិត្តដល់ស្ត្រី និងកុមារដែលរងផលប៉ះពាល់ដោយសារជម្លោះព្រំដែនកម្ពុជា-ថៃ"។ អង្គការចិត្តសង្គមអន្តរវប្បធម៌ កម្ពុជាបានប្រើប្រាស់មូលនិធិនេះដើម្បី៖

- បង្កើតក្រុមគាំទ្រដល់កុមារ និងស្ត្រីដែលងាយរងគ្រោះបំផុត
- ផ្តល់ការប្រឹក្សាបុគ្គលដល់ ស្ត្រី និងកុមារ ដែលរស់នៅក្នុងជំរុំ
- រៀបចំសកម្មភាពកុមារមេត្រី ដែលអនុញ្ញាតឱ្យកុមាររកគូររូប លេងកម្សាន្ត និងចែករំលែកបទពិសោធន៍ដល់មិត្តភក្តិរបស់ពួកគេដែលស្នាក់នៅក្នុងជំរុំ
- ផ្គត់ផ្គង់សម្ភារៈចាំបាច់ដល់ជនភៀសសឹកជាពិសេសដល់ស្ត្រី និងកុមារដែលរួមមាន៖ ធុងទឹក តង់ ទឹកដោះគោស្រស់សម្រាប់កុមារ និងសម្ភារៈសកម្មភាពកុមារមេត្រី។




















REDMI NOTE 11 PRO 5G
06/09/2025 14:27

៩. គម្រោងជួសជុលមណ្ឌលគាំពារកុមារ អង្គការគ្រួសារថ្មី តាខ្មៅ



អង្គការរក្សាកុមារ បានចូលរួមសម្របសម្រួល និងកៀងគរអំណោយដើម្បីគាំទ្រដល់ “គម្រោងជួសជុលមណ្ឌលគាំពារកុមារ អង្គការគ្រួសារថ្មី តាខ្មៅ”។ គម្រោងជួសជុលនេះរួមមាន៖ ការជួសជុលអគារការិយាល័យ បន្ទប់គេង ផ្ទះបាយ បន្ទប់ទឹក កន្លែងអនាម័យ កន្លែងទទួលទានអាហារ និងការងារចាក់ខ្សាច់នៅមណ្ឌលគាំពារកុមារអង្គការគ្រួសារថ្មី តាខ្មៅ។

ជាលទ្ធផល អង្គការគ្រួសារថ្មីបានសម្រេចគោលដៅរបស់ខ្លួន សម្រាប់ឃុទ្ធនាការដែអង្គាសថវិកា ដោយទទួលបានជំនួយឧបត្ថម្ភពីសំណាក់ធនាគារ ABA តាមរយៈអង្គការរក្សាកុមារ។









.

១០. គម្រោងសាងសង់អគារសិក្សា

ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា រវាងអង្គការរក្សាកុមារ និងធនាគារ ឌីជីប៊ី សម្រាប់គម្រោងសាងសង់អគារសិក្សាមួយខ្នងនៅអនុវិទ្យាល័យទីប៉ូ ស្ថិតក្នុងភូមិនិមិត្ត ឃុំទីប៉ូ ស្រុកសន្ទុក ខេត្តកំពង់ធំ។







១១. កម្មវិធីអំណោយសប្បុរសធម៌

១១.១ ម៉ាស៊ីនបញ្ចាំងស្លាយ និងឆ្នាំងបញ្ចាំងស្លាយ (LCD Projectors and Screen Projectors)

អង្គការរក្សាកុមារបានជួយសម្របសម្រួលដល់ការបរិច្ចាគអំណោយរបស់ក្រុមហ៊ុន Autobahn VAG ដល់សាលាចំនួន ៤ នៅក្នុងខេត្តកំពង់ធំ។ ការបរិច្ចាគនេះមានគោលបំណង៖ បំពាក់នូវឧបករណ៍សិក្សាត្រឹមត្រូវដល់សាលារៀន លើកទឹកចិត្តសិស្សឱ្យខិតខំប្រឹងប្រែងរៀនសូត្រ លើកទឹកចិត្តដល់គ្រូបង្រៀនឱ្យស្រលាញ់ការបង្រៀន អប់រំ ណែនាំ និងជំរុញលើកទឹកចិត្តដល់សិស្សានុសិស្សរបស់ខ្លួនឱ្យឈានដល់សក្តានុពលពេញលេញ។ អំណោយដែលបានបរិច្ចាគដោយក្រុមហ៊ុន Autobahn VAG រួមមាន៖

- សាលាបឋមសិក្សាស្នោ-ឃ្លូ ទទួលបានម៉ាស៊ីនបញ្ចាំងស្លាយចំនួន ១គ្រឿង ផ្ទាំងបញ្ចាំងស្លាយចំនួន ១ ព្រមទាំងអំណោយសាច់ប្រាក់ ដល់សិស្សពូកែចំនួន ១២នាក់ និងគ្រូឆ្នើមចំនួន១ នាក់ផងដែរ។
- វិទ្យាល័យហ៊ុនសែនស្រះបន្ទាយ ទទួលបានម៉ាស៊ីនបញ្ចាំងស្លាយចំនួន ១គ្រឿង ផ្ទាំងបញ្ចាំងស្លាយចំនួន១ និងកុំព្យូទ័រយួរដៃម៉ាកLenovo ចំនួន១គ្រឿង។
- សាលាបឋមសិក្សាកំពង់ថ្ម ទទួលបានម៉ាស៊ីនបញ្ចាំងស្លាយចំនួន ១គ្រឿង ផ្ទាំងបញ្ចាំងស្លាយចំនួន១។
- វិទ្យាល័យតាំងក្រសាំង បានទទួលម៉ាស៊ីនបញ្ចាំងស្លាយចំនួន ៤គ្រឿង ផ្ទាំងបញ្ចាំងស្លាយចំនួន៤ អំណោយថវិកាដល់សិស្សពូកែបំផុតចំនួន ពានាក់ សិស្សឆ្នើមចំនួន ៦នាក់ និងសិស្សដែលខ្វះខាតចំនួន ពានាក់។











១១.២ អំណោយកុំព្យូទ័រយួរដៃ



អង្គការរក្សាកុមារ បានផ្តល់កុំព្យូទ័រយួរដៃចំនួន ៥០គ្រឿង ជូនដល់អង្គការ PSE (Pour un Sourire d'Enfant)។ កុំព្យូទ័រយួរដៃចំនួន ៥០គ្រឿងនេះ ជាអំណោយបរិច្ចាគពី ធនាគារ ABA ចំនួន ៣០គ្រឿង និងក្រុមហ៊ុន ទ្រូម៉ាន់នី ចំនួន ២០គ្រឿង។











១១.៣ អំណោយកុំព្យូទ័រយួរដៃ

អង្គការរក្សាកុមារ បានផ្តល់កំព្យូទ័រលើតុ ចំនួន ៥០គ្រឿង ជូនដល់អនុវិទ្យាល័យចំនួន ៣ និងសាលាបឋមសិក្សាចំនួន ១៣ ស្ថិតនៅក្នុងឃុំជ្រាប់ និងឃុំទីពោ ស្រុកសន្ទុក ខេត្តកំពង់ធំ។ កំព្យូទ័រលើតុ ចំនួន ៥០គ្រឿងនេះជាអំណោយបរិច្ចាគពី ធនាគារ ស៊ុនហាន (ខេមបូឌា) ម.ក។








១១.៤ អំណោយឈុតតុ និងកៅអីសម្រាប់សិស្សានុសិស្ស

អង្គការរក្សាកុមារ បានផ្តល់ឈុតតុ និងកៅអីសម្រាប់សិស្សានុសិស្សចំនួន ៦០ ជូនដល់សាលាបឋមសិក្សា តាំងក្រសាំង ស្ថិតនៅក្នុងស្រុកសន្ទុក ខេត្តកំពង់ធំ។ ជំនួយថវិកាសម្រាប់ឈុតតុ និងកៅអី ជាការឧបត្ថម្ភរបស់ ធនាគារ ស៊ុនហាន (ខេមបូឌា) ម.ក។







១២. កម្មវិធីជំនួយឧបត្ថម្ភផ្សេងៗ

- **ទិវាជនមានពិការភាពអូទីស្សឹម និងដោនស៊ីនដ្រូម នៅកម្ពុជា**



អង្គការរក្សាកុមារ បានជួយឧបត្ថម្ភថវិការដល់ ក្រុមប្រឹក្សាសកម្មភាពជនពិការ សម្រាប់ទិវាជនមានពិការភាពអូទីស្សឹម និងដោនស៊ីនដ្រូមកម្ពុជា លើកទី១២ ឆ្នាំ២០២៥ ដើម្បីផ្សព្វផ្សាយឱ្យមានការយល់ដឹងឱ្យបានកាន់តែទូលំទូលាយ អំពីសិទ្ធិ និងសក្តានុពលរបស់ជនមានពិការភាពអូទីស្សឹម និងដោនស៊ីនដ្រូម។

- **ទិវាសុខភាពផ្លូវចិត្ត**



អង្គការរក្សាកុមារ បានជួយឧបត្ថម្ភថវិកាដល់នាយកដ្ឋានចិត្តវិទ្យា នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដើម្បីប្រារព្ធទិវាសុខភាពផ្លូវចិត្តពិភពលោក ដើម្បីបង្កើនការយល់ដឹង និងកាត់បន្ថយការរើសអើងជុំវិញបញ្ហាសុខភាពផ្លូវចិត្តក្នុងសង្គម។







▪ ទិវាជនមានពិការភាព

អង្គការរក្សាកុមារ បានជួយឧបត្ថម្ភដល់ ក្រុមប្រឹក្សាសកម្មភាពជនពិការ ដើម្បីប្រារព្ធទិវាជនមានពិការភាពកម្ពុជាលើកទី២៧ និងអន្តរជាតិលើកទី៤៣ ឆ្នាំ២០២៥ ក្រោមប្រធានបទ «បរិយាបន្នពិការភាពលើគ្រប់វិស័យ ដើម្បីលើកកម្ពស់វឌ្ឍនភាពសង្គម»។ ទិវានេះសង្កត់ធ្ងន់លើការលើកកម្ពស់សិទ្ធិ សុខុមាលភាព និងការចូលរួមរបស់ជនមានពិការភាព។









ទីស្នាក់ការកណ្តាល ផ្ទះលេខ Elysée B២-០០៩ ផ្លូវកោះពេជ្រ
ក្រុមទី៧៨ ភូមិ១៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

(+៨៥៥ ៩៦ ៥៩១ ៦៥៨៨) | (៨៥៥ ១២ ៨២២ ៦៤២)

info@raksakoma.org | www.raksakoma.org